ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

# ជំពូកទី៣ - វិធានដើមកំណើតទំនិញ

## កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃអេមីរ៉ាតអារ៉ាប់រួម

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

រៀបចំដោយ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

# មាតិកា

- វិធានដើមកំណើតទំនិញ
- ការបញ្ជាក់ដើមកំណើតទំនិញ
- នីតិវិធី នៃការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

# វិធានដើមកំណើតទំនិញ

ទំនិញដែលមិនទទួលបានទាំងស្រុង ឬមិនបានផលិតទាំងស្រុង ( Not Wholly Obtained )

ទំនិញដែលផលិតបាននៅទីនោះ ចេញទាំងស្រុងពីវត្ថុធាតុមានដើមកំណើតនៃភាគីសមាជិក

ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុង ( Wholly Obtained )

ទំនិញបានបំពេញតាមលក្ខខណ្ឌផ្សេងទៀតនៃជំពូកនេះ

ទំនិញមានដើមកំណើត

# វិធានដើមកំណើតទំនិញ

## ១.១. ការកំណត់ដើមកំណើតទំនិញ

- ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុង ( Wholly Obtained )
- ការផលិត ឬប្រតិបត្តិការមានលក្ខណៈគ្រប់គ្រាន់ ( Sufficient Working or Production )
- ទំនិញសម្រាប់ផលិតបន្ត ( Intermediate Goods )
- វិធានបូកបន្ថែម ( Accumulation )
- វិធានអប្បបរមា ( De minimis )
- ប្រតិបត្តិការ និងដំណើរការអប្បបរមា/មានលក្ខណៈមិនគ្រប់គ្រាន់ ( minimal/ Insufficient Operations and Processes )

# ទំនិញដែលទទួលបាន ឬផលិតទាំងស្រុងក្នុងដែនដី ( Wholly Obtained )

- រុក្ខជាតិ និងផលិតផលពីរុក្ខជាតិ ដែលត្រូវបានដាំដុះ ប្រមូលយក ឬប្រមូលផលពីទីនោះ
- សត្វរស់ ដែលបានកើត និងចិញ្ចឹមនៅទីនោះ
- ទំនិញដែលទទួលបានពីសត្វរស់នៅទីនោះ
- ផលិតផលរ៉ែ និងធនធានធម្មជាតិ
- ទំនិញដែលទទួលបានពីការប្រមាញ់ ការដាក់អន្ទាក់ ការប្រមូលយក ការនេសាទ ឬវារីវប្បកម្មនៅទីនោះ
- ត្រី សំបកខ្យង និងបណ្ដាសត្វ ឬរុក្ខជាតិសមុទ្រមានជីវិតដទៃទៀត ដែលត្រូវបានយកចេញដោយនាវាដែលបានចុះបញ្ជីជាមួយភាគីសមាជិកនោះ ហើយមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីសមាជិកនោះ និងផលិតផលផ្សេងទៀតដែលយកដោយភាគីសមាជិកនោះ ឬប្រជាជននៃភាគីសមាជិកនោះ ពីក្នុងទឹក បាតសមុទ្រ ឬក្រោមបាតសមុទ្រ នៅខាងក្រៅដែនទឹកនៃភាគីសមាជិកនោះ ក្នុងលក្ខខណ្ឌដែលភាគីសមាជិកនោះមានសិទ្ធិទាញយកផលប្រយោជន៍ ពីធនធានធម្មជាតិ ដែលស្ថិតលើទឹកក្នុងបាតសមុទ្រ និងក្រោមបាតសមុទ្រនោះ ដោយអនុលោមតាមច្បាប់អន្តរជាតិ

- ត្រី សំបកខ្យង និងសត្វឬរុក្ខជាតិសមុទ្រមានជីវិតដទៃទៀត ដែលត្រូវបានយកចេញពីសមុទ្រអន្តរជាតិដោយនាវាដែលបានចុះបញ្ជីជាមួយភាគីសមាជិកនោះ និងមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីសមាជិកនោះ
- វត្ថុធាតុដើមទាញយកមកពីទំនិញប្រើប្រាស់រួចដែលបានប្រមូលនៅទីនោះ
- កាកសំណល់ ឬកម្ទេចកម្ទីដែលបានមកពីការទាញយក ការប្រើប្រាស់ ឬដំណើរការផលិតកម្មដែលបានធ្វើឡើងនៅទីនោះ គួរធ្វើឡើងសម្រាប់តែការទាញយកមកវិញនៃវត្ថុធាតុដើមតែប៉ុណ្ណោះ
- ទំនិញដែលបានផលិត ឬទទួលបានទាំងស្រុងនៅទីនោះ ចេញពីទំនិញដែលបានរៀបរាប់ខាងលើ ឬបានមកពីការកែច្នៃចេញពីទំនិញដែលផលិតនៅដំណាក់កាលនៃការផលិតណាមួយ។

# ទំនិញដែលមិនទទួលបានទាំងស្រុង ឬមិនបានផលិតទាំងស្រុង (Not Wholly Obtained)

## ការផលិត ឬប្រតិបត្តិការមានលក្ខណៈគ្រប់គ្រាន់ (Sufficient Working or Production)

- ការផ្លាស់ប្តូរលេខបួនខ្ទង់ដំបូង នៃលេខចំណាត់ថ្នាក់ពន្ធគយ (CTH) សំដៅដល់ វត្ថុធាតុដែលមិនមានដើមកំណើត ដែលបានប្រើក្នុងការផលិតទំនិញបានឆ្លងកាត់ការផ្លាស់ប្តូរនៅក្នុងចំណាត់ថ្នាក់បន្ទាត់ពន្ធគយប្រព័ន្ធសុខដុមនៅកម្រិត៤ខ្ទង់

ឧទាហរណ៍៖ នាំចូលក្រណាត់ Woven Fabric (5515) ធ្វើការផលិត និងនាំចេញ Men's woven Shirt ( 6205)

- សមាសធាតុតម្លៃមានលក្ខណៈសម្បតិគ្រប់គ្រាន់ (QVC) ≥ 40% នៃតម្លៃដឹកជញ្ជូនដល់លើនាវា (FOB) ឬ
- សមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QVC) ≥ 35% នៃតម្លៃផលិតក្នុងរោងចក្រ (Ex-Works Value)
- វិធានជាក់លាក់សម្រាប់ផលិតផល (PSR)

$$QVC = \frac{\text{តម្លៃExWorks ឬ តម្លៃFOB} - \text{V.N.M}}{\text{តម្លៃExWorks ឬ តម្លៃFOB}} \times ១០០ \text{ ឬ}$$

$$QVC = \frac{\text{V.O.M+ថ្លៃពលកម្មផ្ទាល់+ថ្លៃចំណាយសរុប+ប្រាក់ចំណេញ+ថ្លៃចំណាយផ្សេងៗ}}{\text{តម្លៃExWorks ឬ តម្លៃFOB}} \times ១០០$$

# វិធានដាក់លាក់សម្រាប់ផលិតផល (PSR)

- WO / Wholly obtained
- CTC - ការឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ
- SO - ប្រតិបត្តិការជាក់លាក់ ឬតម្រូវការបច្ចេកទេសណាមួយ ដែលបានកំណត់លម្អិតក្នុងនោះ
- QVC - សមាសធាតុតម្លៃមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- N/A - មិនមានវិធានដែលអាចអនុវត្តបាន

(CTC)

ការឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត២ខ្ទង់ (CC)

ការឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត៤ខ្ទង់ (CTH)

ការឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយនៅកម្រិត៦ខ្ទង់ (CTSH)

* * *គ្រប់វត្ថុធាតុដែលមិនមានដើមកំណើត ដែលត្រូវបានប្រើក្នុងផលិតកម្មទំនិញ

| HS Code (១) | បរិយាយផលិតផល (២) | វិធានជាក់លាក់សម្រាប់ផលិតផល (PSRs) | |
|---|---|---|---|
| | | (៣) | (៤) |
| 1401 - 1404 | វត្ថុធាតុដើមជារុក្ខជាតិសម្រាប់វេញក្រង; បណ្ដាផលិតផលរុក្ខជាតិ ដែលពុំមានបញ្ជាក់ និងបញ្ចូលនៅទីតាំងផ្សេងទៀត | all the materials of Chapter 14 used are wholly obtained | N/A |
| 1510, 1512, 1514, 1515 | ប្រេងផ្សេងទៀតដែលបានពីអូលីវ គ្រាប់ឈូករតន៍ គ្រាប់កប្បាស គ្រាប់រុក្ខជាតិរេត កុលហ្សា ប្រេងម៉ាស្តាត ប្រេងរុក្ខជាតិផ្សេងទៀត បណ្ដាប្រភេទខ្លាញ់បានពីពពួកអតិសុខុមប្រាណ និងប្រេងនានា (រាប់បញ្ចូលទាំងប្រេង jojoba) | CTSH or SO (manufactured by refining crude oils) | QVC |
| 2401 | ថ្នាំជក់ឆៅ សំណល់ថ្នាំជក់ | Wholly Obtained | N/A |
| 6101 - 6117 | សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរ ឬមួយ | CC | QVC |
| 6201 - 6217 | សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលមិនធ្វើឡើងពីការចាក់ដោយម្ជុលពីរឬមួយ | CC | QVC |

# ទំនិញសម្រាប់ផលិតបន្ត

- សម្រាប់វត្ថុធាតុមិនមានដើមកំណើតមួយ ដែលត្រូវឆ្លងកាត់ការផលិតមានលក្ខណៈគ្រប់គ្រាន់ ទំនិញសម្រេចនោះត្រូវបានចាត់ទុកថាមានដើមកំណើត ហើយសមាភាគនៃវត្ថុធាតុមិនមានដើមកំណើតដែលមានផ្ទុកក្នុងទំនិញនោះមិនត្រូវបានរាប់បញ្ចូលនោះទេ នៅពេលដែលផលិតផលនោះត្រូវបានប្រើប្រាស់នៅក្នុងការផលិតបន្តជាទំនិញមួយផ្សេងទៀត

# វិធានបូកបន្ថែម

- ទំនិញមានដើមកំណើតនៃភាគីសមាជិកដែលត្រូវបានយកទៅប្រើប្រាស់ក្នុងការកែច្នៃ ឬការផលិតក្នុងដែនដីនៃភាគីសមាជិកម្ខាងទៀតជាវត្ថុធាតុសម្រាប់ទំនិញសម្រេច ត្រូវបានចាត់ទុកជាវត្ថុធាតុមានដើមកំណើតនីក្នុងដែនដីនៃភាគីសមាជិកម្ខាងទៀតនោះ ដែលការកែច្នៃ ឬប្រតិបត្តិការនៃទំនិញសម្រេច ត្រូវបានធ្វើឡើង
- ទោះយ៉ាងណា វត្ថុធាតុដែលមានដើមកំណើតពីភាគីសមាជិក ដែលមិនបានឆ្លងកាត់ការកែច្នៃលើសពីប្រតិបត្តិការអប្បបរមា ឬមានលក្ខណៈមិនគ្រប់គ្រាន់ នៅក្នុងដែនដីភាគីសមាជិកម្ខាងទៀតនោះ ត្រូវតែរក្សាស្ថានភាពដើមកំណើតនៃភាគីសមាជិកដើមនៃវត្ថុធាតុនោះ

# វិធានអប្បបរមា (De minimis)

- បើទោះបីជាបានឆ្លងកាត់ការផលិត ឬប្រតិបត្តិការមានលក្ខណៈគ្រប់គ្រាន់ ទំនិញមួយនឹងត្រូវបានចាត់ទុកថាបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ប្រសិនបើតម្លៃនៃវត្ថុធាតុមិនមានដើមកំណើតទាំងអស់ដែលបានប្រើក្នុងផលិតកម្មទំនិញ ហើយដែលមិនឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយមានតម្លៃមិនលើសពី ១០% នៃតម្លៃ FOB ឬ១៥% នៃតម្លៃផលិតក្នុងរោងចក្រ (Ex-works) នៃទំនិញនោះទេ
- តម្លៃនៃវត្ថុធាតុមិនមានដើមកំណត់ខាងលើ ត្រូវរាប់បញ្ចូលក្នុងតម្លៃនៃវត្ថុធាតុមិនមានដើមកំណើតសម្រាប់ជាតម្លៃបន្ថែមទៅលើតម្រូវការមាតិកាណាមួយសមស្រប

# ទំនិញដែលបានបំពេញតាមលក្ខណ្ឌតម្រូវនៃវិធានដើមកំណើតទំនិញ

## ( minimal/ Insufficient Operations and Processes )

➢ ទំនិញមួយមិនត្រូវចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដី ប្រសិនបើប្រតិបត្តិការខាងក្រោមត្រូវបានប្រព្រឹត្តឡើងផ្តាច់មុខដោយខ្លួនឯង ឬរួមបញ្ចូលគ្នា៖

- ការសម្លាប់សត្វ
- ប្រតិបត្តិការចាំបាច់សម្រាប់ការថែរក្សាទុកទំនិញ អំឡុងពេលដឹកជញ្ជូន ឬរក្សាទុក
- ប្រតិបត្តិការដើម្បីធ្វើឲ្យប្រសើរឡើងនូវការវេចខ្ចប់ ឬគុណភាពទំនិញឆ្លើយតបនឹងទីផ្សារ ឬដើម្បីរៀបចំសម្រាប់ការដឹកជញ្ជូនទំនិញ ដូចជាការបំបែកជាដុំៗ ការដាក់តម្រៀបជាក្រុម និងការចាត់ថ្នាក់នៃកញ្ចប់ និងការវេចខ្ចប់ឡើងវិញជាដើម
- ការផ្គុំដំឡើងសាមញ្ញ
- ការលាយទំនិញដែលមានដើមកំណើតទំនិញខុសៗគ្នា ក្នុងលក្ខខណ្ឌដែលលក្ខណៈនៃទំនិញទទួលបានមិនមានភាពខុសប្លែកខ្លាំងពីលក្ខណៈទំនិញដែលបានលាយបញ្ចូលគ្នា

# ការបញ្ជាក់ដើមកំណើតទំនិញ

- សំអាងដើមកំណើតទំនិញ ស្ថិតក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា-អារ៉ាប់អេមីរ៉ាត រួមមាន៖
  - វិញ្ញាបនបត្រដើមកំណើតក្នុងទម្រង់ក្រដាសមានលក្ខណៈជាច្បាប់ចម្លងទន់ ឬរឹង
  - វិញ្ញាបនបត្របញ្ជាក់ដើមកំណើតកំណត់ក្នុងទម្រង់អេឡិចត្រូនិក (E-Certificate)
  - ប្រតិវេទន៍ដើមកំណើត ដែលបានអនុម័តដោយអ្នកនាំចេញដែលមានការទទួលស្គាល់
- សំអាងដើមកំណើតទាំងនេះមានសុពលភាពរយៈពេល ០១ឆ្នាំ រាប់ចាប់ពីថ្ងៃចេញសំអាងដើមកំណើត
- ផលិតករ ឬអ្នកនាំចេញត្រូវរក្សាទុកឯកសារកំណត់ត្រាគាំទ្រសំខាន់ៗទាំងអស់ដែលបញ្ជាក់ថាទំនិញដែលមានក្នុងសំអាងដើមកំណើតត្រូវបានចេញមានដើមកំណើតក្នុងរយៈពេលយ៉ាងតិច ០៣ឆ្នាំ គិតចាប់ពីថ្ងៃចេញសំអាងដើមកំណើត ឬក្នុងរយៈពេលវែងជាងនេះ

# នីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

- ក្រសួងពាណិជ្ជកម្មបានដាក់ឲ្យប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម

  (**ប្រកាសលេខ ៣១៩៨៧.ណលខ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៦**)
- បច្ចុប្បន្ន អ្នកនាំចេញអាចស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ CAMBODIA-UNITED ARAB EMIRATES COMPREHENSIVE ECONOMIC PARTNERSHIP AGREEMENT (CO FORM CAM-UAE) តាមរយៈគេហទំព័រ https://co.moc.gov.kh សម្រាប់ទំនិញទៅកាន់ទីផ្សារនៃប្រទេសអេមីរ៉ាតអារ៉ាប់រួម
- អនុវត្តកម្រងសេវាសាធារណៈតាមប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣១៥ ...សហវ.ព្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៥៣ | ១៧ ការបញ្ជាក់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្នុងមួយជំពូក | ១០០ ០០០ | ៦០ ថ្ងៃ | |
| ៥៤ | ១៨ ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលកម្ពុជាត្រូវបានជ្រើសរើស ក្នុងមួយជំពូក និងបោះពុម្ពផ្សាយ | ៦០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៥ | ១៩ ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិសាជាថ្មី ក្នុងមួយជំពូក | ៦០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៦ | ២០ ការសុំប្តូរម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាម៉ាកថ្នាក់ជាតិ និងបោះពុម្ពផ្សាយ | ៤២០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៧ | ២១ ការជំនួសម៉ាកជាតិទៅជាម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងបោះពុម្ពផ្សាយ | ១០០ ០០០ | តាមបទប្បញ្ញត្តិនៃការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ | ១០ ឆ្នាំ |
| ៥៨ | ២២ ការស្នើសុំទទួលស្គាល់ជាភ្នាក់ងារតំណាងម្ចាស់ម៉ាក | ១០០ ០០០ | | ១ ឆ្នាំ |
| | **នាយកដ្ឋាននាំចេញ-នាំចូល និងតំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស** | | | |
| | ក. សេវាចេញវិញ្ញាបនបត្រប្រភពដើមទំនិញ | | | |
| | ១ សម្លៀកបំពាក់ | | | |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទម្រង់ A: | | | |
| ៥៩ | ច្រើនជាង ឬ ស្មើ ២ 000PCS | ២១៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦០ | តិចជាង ២ 000PCS | ៨៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ N: | | | |
| ៦១ | ច្រើនជាង ឬ ស្មើ ២ 000PCS | ១៤២ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦២ | តិចជាង ២ 000PCS | ៦៧ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ផ្សេងទៀត | | | |
| ៦៣ | ច្រើនជាង ឬ ស្មើ ២ 000PCS | ២១៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៤ | តិចជាង ២ 000PCS | ៨៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| | ២ ក្រណាត់ | | | |
| ៦៥ | - ទម្រង់ A | ២១៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៦ | - ទម្រង់ N | ១៤២ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៧ | - ទម្រង់ផ្សេងទៀត | ២១៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| | ៣ ស្បែកជើង | | | |
| | - ទម្រង់ A | | | |
| ៦៨ | ច្រើនជាង ឬ ស្មើ ២00PRS | ២១៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |
| ៦៩ | តិចជាង ២00PRS | ៨៦ 000 | ១៦ ម៉ោង | ៦-១២ ខែ |

| លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទម្រង់ N | | | |
| ៧០ | ច្រើនជាង ឬ ស្មើ ២០០PRS | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧១ | តិចជាង ២០០PRS | ៦៧ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | - ទម្រង់ផ្សេងទៀត | | | |
| ៧២ | ច្រើនជាង ឬ ស្មើ ២០០PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៣ | តិចជាង ២០០PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៤ | ៤ អង្ករ (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៥ | ៥ ទំនិញសិប្បកម្មតូច (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៦ | ៦ ទំនិញកសិផល÷ ដំឡូង ពោត សណ្តែក ម្ទេស ល្ង ស្វាយ បន្លែ និងផ្លែឈើផ្សេងៗទៀត (គ្រប់ទម្រង់) | មិនគិតថ្លៃ | ១៦ ម៉ោង | ៦-១២ ខែ |
| | ៧ ទំនិញទូទៅ | | | |
| ៧៧ | - ទម្រង់ A | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៨ | - ទម្រង់ N | ១៤២ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៧៩ | - ទម្រង់ផ្សេងទៀត | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| | ៨ ការកែតម្រូវ ឬ ចេញច្បាប់ទុតិយតានៃវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ | | | |
| | - ទម្រង់ A | | | |
| ៨០ | ច្រើនជាង ឬ ស្មើ ២ ០០០PCS/PRS | ២១៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |
| ៨១ | តិចជាង ២ ០០០PCS/PRS | ៨៦ ០០០ | ១៦ ម៉ោង | ៦-១២ ខែ |

# តម្រូវការឯកសារ

- វិក្កយបត្រ ( invoice )
- តារាងវេចខ្ចប់ ( Packing list )
- តារាងថ្លៃដើមផលិតផល ( Cost breakdown )
- ឯកសារយោងតាមការកំណត់របស់វិធានដើមកំណើតទំនិញ
- របាយការណ៍ស្តីពីការត្រួតពិនិត្យទំនិញនាំចេញដែលមានព័ណ៌ប៉ារ៉ា ពណ៌បៃតង ( ត្រអ៊ុ និង កាគី ) ទំនិញដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជាទៅឡើងយន្តហោះនៅប្រទេសជិតខាង ( Land-air )
- របាយការណ៍ពិនិត្យទំនិញនាំចេញលើកដំបូង
- ឯកសារយោងផ្សេងៗទៀតតាមតម្រូវការរបស់ប្រទេសនាំចូលដោយអនុលោមតាមវិធានដើមកំណើតទំនិញ

- ក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីក្រសួងពាណិជ្ជកម្មបានចេញវិញ្ញាបនបត្រ អ្នកនាំចេញ ត្រូវផ្ញើឯកសារច្បាប់ដើមដូចបានកំណត់មកនាយកដ្ឋាននាំចេញ នាំចូលមាន៖
  - វិញ្ញាបនបត្របញ្ជាក់ដើមកំណើត (ច្បាប់ថតចម្លង)
  - វិក្កយបត្រ (invoice)
  - តារាងវេចខ្ចប់ (Packing list)
  - អញ្ញត្តិបណ្ណដឹកជញ្ជូន និង
  - ប្រតិវេទន៍គយនាំចេញ

- ឧបសម្ព័ន្ធជំនួសវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ក្រោយទទួលការឯកភាពរួចហើយ ផលិតករ ឬអ្នកនាំចេញត្រូវភ្ជាប់មក
  - វិក្កយបត្រ (invoice)
  - តារាងវេចខ្ចប់ (Packing list)
  - អញ្ញត្តិបណ្ណដឹកជញ្ជូន និង
  - ប្រតិវេទន៍គយនាំចេញ នៅពេលយកមកតម្កល់នៅក្រសួងពាណិជ្ជកម្ម

# ទម្រង់

**Original**

1. Exporter's Name, Address, Country

2. Producer's Name, Address, Country

3. Consignee's Name and Address, Country

*CERTIFICATE NO.*

CAMBODIA-UNITED ARAB EMIRATES
COMPREHENSIVE ECONOMIC PARTNERSHIP AGREEMENT
CERTIFICATE OF ORIGIN

Issued in ______________
(Country)

See Overleaf Notes

4. Means of transport and route, provided it is known.

Departure date:

Vessel's name/Aircraft etc.:

Port of Loading:

Port of Discharge:

For Official Use
☐ Preferential Tariff Treatment Given Under Cambodia -UAE CEPA
☐ Preferential Tariff Treatment Not Given (Please state reason/s)

.................................................................................................
Signature of Authorized Signatory of the Importing Party

5.☐ Third party invoice (Name and Address)

6.Remarks

| 7. Item number | 8a. Marks and numbers on packages; | 8b. Number and kind of packages; description of goods; HS code in six digits | 9. Origin Criteria | 10. Gross Weight, or other quantity and Value (FOB/ Ex-Work only when QVC criterion is used) | 11. Number and date of invoices |
|---|---|---|---|---|---|
| | | | | | |

SPECIMEN

12. Declaration by the exporter

The undersigned hereby declares that the above details and statement are correct; that all the goods were produced in

.................................................................................................
(Country)

and that they comply with the origin requirements specified for these goods in the Cambodia-UAE CEPA for the goods exported to

.................................................................................................
(Importing Country)

.................................................................................................
Place and date, signature and stamp of authorized signatory

13. Certification

**On the basis of control carried out, it is hereby certified that the information herein is correct and that the goods described comply with the origin requirements specified in the Cambodia-United Arab Emirates Comprehensive Economic Partnership Agreement.**

.................................................................................................
Place, Date, signature and stamp
of Competent Authority

## OVERLEAF NOTES

**Box 1:** State the full legal name, address, (including country) of the exporter.

**Box 2:** Provide the producer of the goods (name and country). If the producer and the exporter are the same, complete box with the details as on Box 1. If the exporter or the producer wishes this information to be confidential, then it is acceptable to state "Available to the competent authority or authorized body upon request".

**Box 3:** State the full legal name, address (including country) of the consignee.

**Box 5: Third-party invoice:** In the case where invoices are issued by a third party, the "third party invoice" box should be ticked (√) and such information as the name and address of the company issuing the invoice shall be indicated. In an exceptional case where the invoice issued by a third party is not available at the time of issuance of the certificate of origin, the invoice number and the date of the invoice issued by the exporter to whom the certificate of origin is issued should be indicated in box 11, and it should be indicated in box 5 that the goods will be subject to another invoice to be issued by a third party for the importation into the importing Party, identifying the full legal name and address of the company or person that will issue another invoice. In such case, the Customs Authority of the importing Party may require the importer to provide the invoices and any other relevant documents which confirm the transaction from the exporting Party to the importing Party, with regard to the goods declared for import.

**Box 6: Remarks:** This box shall bear observations made by the country of exportation, for example:

**"Issued retroactively":** In exceptional cases where a Certificate of Origin has not been issued prior to or at the time of shipment or the Certificate of Origin may be issued retroactively, in accordance with paragraph 1 of Article 3.25
**"Certified True Copy"** in case of loss or destruction of the original Certificate of Origin as per Article 3.26
**"Replacement":** in case of issuing a replacement Certificate of Origin in accordance to Article 3.28, indicate the number of the previous Certificate of Origin.

**Box 7:** State the item number.

**Box 8a:** Shipping Marks and numbers on the packages shall also be specified.

**Box 8b:** Provide a full description of each good. The description should be sufficiently detailed to enable the products to be identified by the Customs Officers examining them and relate it to the invoice description and to the HS description of the good. The Harmonized System number should be at six-digit level.

ORIGIN CRITERIA: For goods that meet the origin criteria, the exporter or producer must indicate in box 9 of this Form, the origin criteria met, in the manner shown in the following table:

| Origin Criteria | |
|---|---|
| (a) Goods wholly obtained or produced in the country of exportation satisfying Article 3.3 | "WO" |
| (b) Goods satisfying Article 3.4 | |
| • Change in Tariff Classification | The actual CTC rule, example "CC" or "CTH" or "CTSH" |
| • Qualifying Value Content | "QVC%", Example "40%" |
| • Specific Operations | "SO" |
| (c) Goods Produced Exclusively from originating materials as per paragraph c of Article 3.2 | "PE" |

**Box 11:** Invoice number and date of invoices should be shown here.

SPECIMEN

# កំណត់ចំណាំ

វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញមុន ឬអំឡុងពេលដឹកជញ្ជូន

➢ **បញ្ជាក់ពាក្យ " ISSUED RETROACTIVELY"**

ក្នុងករណីលើកលែងតែនៅពេលដែលCOមិនត្រូវបានចេញមុន/អំឡុងពេលដឹកជញ្ជូន ដោយសារកំហុស/ការរំលងដោយអចេតនា ឬមូលហេតុសមស្របណាមួយ COនេះអាចចេញជាលក្ខណៈប្រតិសកម្ម ប៉ុន្តែមានសុពលភាពមិនលើសពីមួយឆ្នាំ គិតចាប់ពីថ្ងៃដឹកជញ្ជូនដែលចាំបាច់ត្រូវ

➢ **បញ្ជាក់ពាក្យ "CERTIFIED TRUE COPY"**

ក្នុងករណីបាត់បង់ ចោរលួច ឬត្រូវបានបំផ្លាញ អ្នកផលិត ឬអ្នកនាំចេញអាចស្នើសុំសេចក្តីចម្លងច្បាប់ដើមនៃ CO ដែលមានហត្ថលេខាអាជ្ញាធរចេញវិញ្ញាបនបត្រ ត្រាផ្លូវការ និងមានពាក្យ (CERTIFIED TRUE COPY) ព្រមនឹងកាលបរិច្ឆេទចេញដែលមានសុពលភាពដូចគ្នាទៅនឹងCOច្បាប់ដើម

➢ **បញ្ជាក់ពាក្យ "Replacement"**

ការកោសលុប ឬសរសេរត្រួតលើគ្នា មិនត្រូវបានអនុញ្ញាតឲ្យមានលើ CO ឡើយ

ក្នុងករណីមានការកែប្រែណាមួយត្រូវធ្វើឡើង គប្បីត្រូវប្រើប្រាស់COថ្មី ជំនួសCOចាស់ដែលមានកំហុស នឹងមានបញ្ជាក់ពាក្យ Replacement អមជាមួយលេខយោងនៃCOច្បាប់ដើម

# ទិន្នន័យនាំចេញទំនិញទៅអារ៉ាប់អេមីរ៉ាត

by Certificate of Origin

| No. | Description | Unit | 2022 | | 2023 | | 10 M 2024 | |
|---|---|---|---|---|---|---|---|---|
| | | | QTY | Amount ( USD ) | QTY | Amount ( USD ) | QTY | Amount ( USD ) |
| 1 | GARMENT | PC | 7,343,858.00 | 46,090,767.28 | 6,998,457.00 | 46,207,779.93 | 5,919,689 | 32,928,753.94 |
| 2 | FOOTWEAR | PRS | 997,138.00 | 12,017,006.26 | 1,872,228.00 | 15,013,733.13 | 1,537,978 | 12,065,058.70 |
| 3 | AGRICULTURAL PRODUCTS | KG | 100,865.00 | 58,200.00 | 37,500.00 | 50,200.00 | 344,862 | 358,309.41 |
| 4 | OTHER PRODUCTS | N/A | 497,117.50 | 5,072,830.96 | 958,700.00 | 5,278,077.28 | 597,203.00 | 3,200,912.55 |
| | **GRAND TOTAL** | | **8,938,978.50** | **63,238,804.50** | **9,866,885.00** | **66,549,790.33** | **8,399,731.65** | **48,553,034.60** |

ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល

# សូមអរគុណ